**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
## របស់ការិយាល័យអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ការិយាល័យអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ក្រសួងបានរៀបចំកិច្ចប្រជុំជាមួយតំណាងអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ ដើម្បីពិនិត្យនិងពិភាក្សាអំពីការអនុវត្តកិច្ចធានាឱ្យបាននៅក្រៅឃុំជាបណ្តោះអាសន្នរបស់តំណាងអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍។ សូមបញ្ជាក់ផងដែរថា កន្លងមក តំណាងអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ ក៏បានស្នើសុំឱ្យក្រសួងជួយធ្វើអន្តរាគមន៍ឱ្យបាននៅក្រៅឃុំជាបណ្តោះអាសន្ន ដើម្បីចូលរួមដោះស្រាយវិវាទជាមួយក្រុមហ៊ុន ណាហ្គាវើលដ៍ ដោយបានសន្យាថា មិនបន្តធ្វើការប្រមូលផ្តុំ ឬដឹកនាំតវ៉ាណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមជាតិឡើយ។ ប៉ុន្តែ ជាក់ស្តែង ក្រសួងបានសង្កេតឃើញថា បងប្អូនអតីតបុគ្គលិកនៅតែបន្តធ្វើការប្រមូលផ្តុំ ឬដឹកនាំតវ៉ា ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដដែល។ ភាគីតំណាងអតីតបុគ្គលិកបានចូលរួមប្រជុំ រួមមាន លោកស្រី ឈឹម សុខន, លោកស្រី ឃ្លាំង សុបិន្ត, លោកស្រី ហៃ សុភាព និងលោកស្រី រី សុវណ្ណឌី ចំណែកតំណាងអតីតបុគ្គលិកផ្សេងទៀតបានអវត្តមាន ដោយសារកំពុងនៅខេត្ត និងមានធុរៈផ្ទាល់ខ្លួន។

ក្នុងកិច្ចប្រជុំនេះ ក្រសួងបានក្រើនរំលឹកអំពីការសន្យារបស់តំណាងអតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ និងស្នើឱ្យរាយការណ៍អំពីស្ថានភាពនៃការអនុវត្តការសន្យានោះ ព្រមទាំងបានណែនាំឱ្យតំណាងអតីតបុគ្គលិកទាំងនោះបន្តអនុវត្តតាមការសន្យាថា មិនបន្តធ្វើការប្រមូលផ្តុំឬដឹកនាំតវ៉ាណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមជាតិឡើយ។

ក្រសួងក៏បានជម្រាបជូនសមាជិកអង្គប្រជុំផងដែរថា ក្រសួងស្វាគមន៍ក្នុងការផ្តល់សេវាប្រឹក្សាផ្នែកច្បាប់ជូនអតីតបុគ្គលិកដែលបានអនុញ្ញាតឱ្យនៅក្រៅឃុំ និងបានស្នើឱ្យតំណាងអតីតបុគ្គលិកទាំងនោះផ្តល់ការសហការ និងរាយការណ៍ជូនក្រសួង ក្នុងករណីចាំបាច់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃសុក្រ ១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២